

# ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

## របាយការណ៍ប្រចាំត្រីមាសទី ១ ឆ្នាំ ២០២៣

(គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣)



# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ត្រីមាសទី១ ឆ្នាំ ២០២៣<br>*(បានត្រួតពិនិត្យឡើងវិញ)* | ឆ្នាំ ២០២២<br>*(បានធ្វើសវនកម្មរួច)* |
|---|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ (ពាន់រៀល)** | | | |
| ទ្រព្យសកម្មសរុប | | ៦៨.១៨៤.៣៥៥ | ៦០.៧៥១.៧៣១ |
| បំណុលសរុប | | ៣៥.០៧៤.៨៦០ | ២៩.២៣៦.៣៩០ |
| មូលធនសរុប | | ៣៣.១០៩.៤៩៥ | ៣១.៥១៥.៣៤១ |
| **លទ្ធផលហិរញ្ញវត្ថុ (ពាន់រៀល)** | | **ត្រីមាសទី១ ឆ្នាំ ២០២៣**<br>*(បានត្រួតពិនិត្យឡើងវិញ)* | **ត្រីមាសទី១ ឆ្នាំ ២០២២**<br>*(បានត្រួតពិនិត្យឡើងវិញ)* |
| ចំណូលសរុប | | ១៦.៣៧៦.៩៨៧ | ១៦.១៦៩.៣៥០ |
| ចំណេញ/(ខាត)មុនបង់ពន្ធ | | ២.៤៤៦.១៣៧ | ១.៦៦៦.៨២៥ |
| ចំណេញសុទ្ធ/(ខាត)ក្នុងការិយបរិច្ឆេទ | | ២.០៩១.៧៨១ | ១.៥៥៧.៣២៣ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ១.៥៩៤.១៥៥ | ១.៣៣៥.៧៨២ |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទី១ ឆ្នាំ ២០២៣**<br>*(បានត្រួតពិនិត្យឡើងវិញ)* | **ឆ្នាំ ២០២២**<br>*(បានធ្វើសវនកម្មរួច)* |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ១,៧១ ដង | ១,៦៣ ដង |
| | អនុបាតចរន្តលឿន | ១,៥១ ដង | ១,៤៣ ដង |
| | | **ត្រីមាសទី១ ឆ្នាំ ២០២៣**<br>*(បានត្រួតពិនិត្យឡើងវិញ)* | **ត្រីមាសទី១ ឆ្នាំ ២០២២**<br>*(បានត្រួតពិនិត្យឡើងវិញ)* |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (%) | ២,៣៤ | ២,២០ |
| | អនុបាតចំណេញធៀបនឹងមូលធន(%) | ៤,៨១ | ៤,២៤ |
| | អនុបាតគម្លាតចំណេញដុល(%) | ២៦,៦៣ | ២៣,៨៧ |
| | អនុបាតគម្លាតចំណេញភាព(%) | ៩,៧៣ | ៨,២៦ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ១១០ រៀល | ៩០ រៀល |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | ៦,៧៣ | ៤,៤៨ |

## ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

❖ ស្ថានភាពហិរញ្ញវត្ថុប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ (ពាន់រៀល)




❖ ចំណេញ/ (ខាត) ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ (ពាន់រៀល)




❖ បម្រែបម្រួលថ្លៃភាគហ៊ុនក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០២៣



## សមាសភាពក្រុមប្រឹក្សាភិបាល



**លោក នាង វិធី**
ប្រធានក្រុមប្រឹក្សាភិបាល
និង នាយកគ្រប់គ្រង



**លោក ថៃ វ៉ាន់ថា**
អភិបាលមិនប្រតិបត្តិ



**លោកស្រី លឹម មុយលី**
អភិបាលមិនប្រតិបត្តិ និង នាយកហិរញ្ញវត្ថុ



**លោក RAMI Bashir Asad Sharaf**
អភិបាលមិនប្រតិបត្តិ



**លោក ហ៊ុយ វ៉ាថារ៉ូ**
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល



តំណាងអោយក្រុមហ៊ុន **ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** និងជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ របស់យើងខ្ញុំ ដោយគិតចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ជូនភាគីពាក់ព័ន្ធ និងសាធារណជនទាំងអស់។

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រុមហ៊ុនទទួលបាន**ប្រាក់ចំណូលសរុប** ១៦ ៣៧៦ ៩៨៧ ពាន់រៀល ដែលមានការ**កើនឡើង**ចំនួន ១,២៨% បើធៀបនឹងប្រាក់ចំណូលសរុប ១៦ ១៦៩ ៣៥០ ពាន់រៀល ក្នុងត្រីមាសទី១ ឆ្នាំ២០២២។ ដោយឡែក ក្រុមហ៊ុនទទួលបាន**ចំណេញលម្អិតក្នុងការិយបរិច្ឆេទ**ចំនួន ១ ៥៩៤ ១៥៥ ពាន់រៀល សម្រាប់ត្រីមាសនេះ ដែល**កើនឡើង**ចំនួន ១៩,៣៤% បើធៀបនឹងចំណេញលម្អិតក្នុងការិយបរិច្ឆេទសម្រាប់ត្រីមាសទី១ ឆ្នាំ២០២២ មានចំនួន ១ ៣៣៥ ៧៨២ ពាន់រៀល។ ទ្រព្យសកម្មសរុបកើនឡើង ១២,២៣ % បើធៀបនឹងឆ្នាំ ២០២២ ដែលកើនពី ៦០ ៧៥១ ៧៣១ ពាន់រៀល មក ៦៨ ១៨៤ ៣៥៥ ពាន់រៀល។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិក សម្រាប់ដំបូន្មានល្អៗ និងការខិតខំប្រឹងប្រែងរបស់អ្នកទាំងអស់គ្នា សម្រាប់ការរីកចម្រើនប្រកបដោយនិរន្តរភាពរបស់ក្រុមហ៊ុន។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះនិយ័តករមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលផ្តល់ទំនុកចិត្ត និងការគាំទ្រដល់ក្រុមហ៊ុន ឌី ប៊ី ឌី។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភាឆ្នាំ២០២៣

ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក
DBD ENGINEERING Plc.
KINGDOM OF CAMBODIA

**លោក ឆាង វិជី**

ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង

មាតិកា

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ... ii

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ... iii

**សមាសភាពក្រុមប្រឹក្សាភិបាល** ... iv

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ... v

**ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** ... 1

ក-អត្តសញ្ញាណរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ... 1

ខ-លក្ខណៈនៃធុរកិច្ច ... 1

**ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ... 3

ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ... 3

ខ-រចនាសម្ព័ន្ធចំណូល ... 5

**ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ... 7

**ផ្នែកទី ៤៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ... 8

ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ... 8

ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ... 11

គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ... 12

ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ... 12

ង-ផលប៉ះពាល់នៃអតិផរណា ... 13

ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ... 13

**ផ្នែកទី ៥៖ ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន** ... 14

**ហត្ថលេខាអភិបាលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

## ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

## ក-អត្តសញ្ញាណរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** (ឌី ប៊ី ឌី) |
| ជាអក្សរឡាតាំង | DBD Engineering Plc. |
| អក្សរកូដ | KH១០០០១៥០០០៨ |
| ទីស្នាក់ការ | ដីឡូតិ៍ ១២៩៨ ផ្លូវ បេតុង ភូមិស្វាយចេក សង្កាត់គោករការ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរសព្ទ | (+៨៥៥) ៧៨ ៧០០ ៥៩៨ |
| គេហទំព័រ | www.dbdengineering.com |
| អ៊ីម៉ែល | services@dbdengineering.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៤០២៩ ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៩៨ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ១២៣/២១ ស.ស.រ/ន.ម.ក. ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ |
| ឈ្មោះបុគ្គលក្រុមហ៊ុន | លោក **នាង វិធី** |

## ខ-លក្ខណៈនៃធុរកិច្ច

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ជាក្រុមហ៊ុនពហុមុខងារ ផ្នែកវិស្វកម្ម និងសំណង់ដែលមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងព្រះរាជាណាចក្រកម្ពុជា។ ឌី ប៊ី ឌី ផ្តល់សេវាកម្មដូចជា សេវាគូសប្លង់ សាងសង់ដំឡើង និងថែទាំ ដែលសេវាកម្មទាំងនេះធ្វើឱ្យក្រុមហ៊ុនទទួលកេរ្តិ៍ឈ្មោះលំដាប់ជាតិ និងអន្តរជាតិ។ ឌី ប៊ី ឌី ទទួលបានកំណត់ត្រាល្អក្នុងការផ្តល់សេវាកម្ម និងផ្គត់ផ្គង់ផលិតផលប្រកបដោយគុណភាពខ្ពស់ដែលស្តែងបញ្ជាក់តាមរយៈការពេញចិត្ត និងការសរសើរពីសំណាក់អតិថិជនរបស់ខ្លួន។

អគ្គិសនី និងសំណង់



មេកានិច និងអគ្គិសនី



ការចុះត្រួតពិនិត្យ និងថែទាំអគារ



កម្តៅ ខ្យល់ចេញចូល និងប្រព័ន្ធម៉ាស៊ីនត្រជាក់



ឌី ប៊ី ឌី មានបុគ្គលិកជំនាញផ្នែកសេវាកម្ម និងការថែទាំ ដើម្បីធានា និងរក្សាគុណភាពជាប់រឹងមាំរបស់សំណង់អគារ និងការបំពាក់ឧបករណ៍ថ្មី ហើយបច្ចុប្បន្ននេះ ឌី ប៊ី ឌី បាននឹងកំពុងពង្រីកអាជីវកម្មផ្នែក ផលិតកម្មលើប្រព័ន្ធបំពង់ គ្រឿងចក្រ ការថែរក្សារោងចក្រ និងឧបករណ៍។

## ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

នាដើមឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទទួលបានគម្រោងដំបូងគេ គឺការសាងសង់ និងដំឡើងប្រព័ន្ធ MEP របស់អាគារ "WING OFFICE TOWER" ដែលមានទីតាំងស្ថិតនៅមហាវិថីព្រះមុនីវង្ស និងមហាវិថីកម្ពុជាក្រោម ក្នុងសង្កាត់មនោរម្យខណ្ឌ ៧ មករា រាជធានីភ្នំពេញ។ គម្រោងនេះបានចាប់ផ្តើមធ្វើការសាងសង់ក្នុងឆ្នាំ ២០២២ និងបញ្ចប់គម្រោងក្នុងឆ្នាំ ២០២៣ នាពេលខាងមុខ។ បន្ថែមពីនេះក្រុមហ៊ុន ឌី ប៊ី ឌី ក៏សម្រេចទទួលយកគម្រោងធំមួយទៀតខាងផ្នែកសាងសង់ទាំងមូលទៅលើ គម្រោង "BIOMASS STEAM BOILER PLANT" ពីខាងក្រុមហ៊ុន BECIS ដែលនឹងផលិតថាមពលដោយចំហាយ និងផ្គត់ផ្គង់ទៅអោយ ក្រុមហ៊ុន HEINEKEN ។

ជាមួយគ្នានេះ ក្រុមហ៊ុន ឌី ប៊ី ឌី បានចូលរួមសាងសង់ និងបន្តសាងសង់គម្រោងធំៗមានដូចជា ផ្សារទំនើបអ៊ីអនទី១, ផ្សារទំនើបអ៊ីអនទី២, គម្រោងខុនដូ NORTH PARK, គម្រោង ជីប ម៉ុង សែនសុខ, គម្រោងផ្សារទំនើប ជីប ម៉ុង ៥៩៨, និងគម្រោងផ្សារទំនើប ជីប ម៉ុង ២៧១ ជាដើម។

បច្ចុប្បន្នក្រុមហ៊ុនកំពុងធ្វើការលើប្រព័ន្ធថ្មីសម្រាប់ការគ្រប់គ្រងធនធានមនុស្សដែលជួយឱ្យអ្នកគ្រប់គ្រងទទួលបានរបាយការណ៍ផ្ទាល់កាន់តែងាយស្រួលលើការរៀបចំ និងការត្រួតពិនិត្យកម្លាំងពលកម្ម ដើម្បីកាត់បន្ថយការខ្វះខាតកម្លាំងពលកម្ម។ បន្ថែមពីនេះ ក្រុមហ៊ុនក៏អនុវត្តមុខងារថ្មីនៅក្នុងប្រព័ន្ធគណនេយ្យបច្ចុប្បន្នផងដែរ ដើម្បីគ្រប់គ្រងការថ្លៃដើមសម្ភារៈ។

### គម្រោងថ្មី នៃត្រីមាសទី១ ឆ្នាំ២០២៣

| គម្រោង | កាលបរិច្ឆេទរំពឹងទុកនៃការបញ្ចប់គម្រោង |
|---|---|
| FTB Tower-HVAC | កុម្ភៈ ២០២៥ |
| OJI Factory | ធ្នូ ២០២៣ |
| Wing PBC Phase 2 | ១៩ មិថុនា ២០២៣ |
| Wing Tower-I.D Lighting | ២០ មិថុនា ២០២៣ |
| Wing Tower-Façade Lighting | ២០ មិថុនា ២០២៣ |
| Wing Tower – AV Work Package | ២០ មិថុនា ២០២៣ |

## គម្រោងស្ថិតក្នុងដំណើរការ

| គម្រោង | កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | លទ្ធផលសម្រេចបាន |
|---|---|---|
| WING Tower | ៦ មករា ២០២២ | ៨៣.០២% |
| DBD New HQ | ៧ ធ្នូ ២០២១ | ៩៣% |
| WING Tower- LED Screen | មិថុនា ២០២២ | ២៨% |
| Chip Mong 271 Mega Mall | កក្កដា ២០២០ | ៩៩,៩៥% |
| Wing Tower-ID Lighting | មករា ២០២២ | ២៨% |
| B-Quick Aeon 3 | ២៧ មីនា ២០២៣ | ១.៨% |
| Tenant Cinema | ៥ សីហា ២០២២ | ៩៩,២១% |
| Wing PBC 2 | ២១ មីនា ២០២៣ | ៣៧% |
| Tenant CMG Office | | ៩៨% |




❖ គម្រោង BIOMASS STEAM BOILER PLANT




គម្រោងអាគារ WING OFFICE TOWER



គម្រោង CHIP MONG MEGA MALL 271




គម្រោង CHIP MONG SENSOK MALL




គម្រោង WING BANK



គម្រោង TRIBE HOTEL Phnom Penh

## ខ-រចនាសម្ព័ន្ធចំណូល

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានប្រភពចំណូលពីរ ដែលចំណូលទី ១ គឺបានមកពីគម្រោងសាងសង់ដែលជាប្រភពចម្បង ក្នុងនោះរួមបញ្ចូលនូវគម្រោងថ្មី និងការងារជួសជុល និងការថែទាំ។ ប្រភពចំណូលទី ២ គឺបានមកពីការលក់សម្ភារៈគម្រោង ដែលវាជាផ្នែកតូចមួយរបស់ចំណូលសរុប។ ទោះបីជាយ៉ាងណាក៏ដោយ ប្រាក់ចំណូលពីការលក់សម្ភារៈគម្រោង នឹងមានការកើនឡើងបន្ទាប់ពីក្រុមហ៊ុនពង្រីកនូវផលិតកម្មបំពង់របស់ខ្លួន។ ក្រុមហ៊ុន ឌី ប៊ី ឌី នឹងធ្វើការលក់ផលិតផលនេះ ដែលសព្វថ្ងៃនេះក្រុមហ៊ុនផលិតសម្រាប់តែផ្គត់ផ្គង់គម្រោងសាងសង់របស់ខ្លួនប៉ុណ្ណោះ។

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ២០២៣ | | ត្រីមាសទី១ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (ពាន់រៀល) | ភាគរយ | ចំនួនទឹកប្រាក់ (ពាន់រៀល) | ភាគរយ |
| ១ | ចំណូលពីគម្រោងសាងសង់ | ១៦.៣៤៤.២៥៨ | ៩៩,៨០% | ១៦.០៨៧.៧៦៩ | ៩៩,៥០% |
| ២ | ចំណូលពីការលក់ទំនិញ | ៣២.៧២៩ | ០,២០% | ៨១.៥៨១ | ០,៥០% |
| ចំណូលសរុប | | **១៦.៣៧៦.៩៨៧** | **១០០%** | **១៦.១៦៩.៣៥០** | **១០០%** |

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី មានចំណូលសរុបចំនួន ១៦.៣៧៦.៩៨៧ ពាន់រៀល ដែលកើនឡើងចំនួន ២០៧.៦៣៧ ពាន់រៀល ស្មើនឹង ១,២៨ ភាគរយ បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០២២។ ការកើនឡើងនេះបណ្តាលមកពីចំណូលពីគម្រោងសាងសង់កើនឡើងចំនួន ១,៥៩ ភាគរយ។

## ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ។

## ផ្នែកទី ៤.- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុដោយគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។ គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលបានជះឥទ្ធិពលទៅ លើប្រាក់ចំណេញរបស់ក្រុមហ៊ុន ឌី ប៊ី ឌី តែប៉ុណ្ណោះ។

### ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានបង្កើតឡើងនៅឆ្នាំ១៩៩៨ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនម៉ៅការសាងសង់ឯកទេសផ្នែក MEP និងសំណង់ស៊ីវិល ដែលផ្តល់សេវាកម្មលើផ្នែកមេកានិច អគ្គិសនី ប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ ម៉ាស៊ីនត្រជាក់ បន្ទប់ត្រជាក់ HVAC និងថែទាំអគារ។

#### ១-ការវិភាគចំណូល

ប្រភពចំណូលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក គឺបានពីសេវាសាងសង់ និងសេវាថែទាំ រួមទាំងការងារ MEP និងការងារសំណង់ស៊ីវិល ហើយចំណូលសរុបត្រូវបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយធ្វើការបែងចែកជា ៣ (បី) ផ្នែកដូចជា៖ (១).ការសាងសង់ និងសេវាកម្មថែទាំ, (២).ការលក់ទំនិញ និង (៣).ចំណូលផ្សេងៗ។ ចំណូលត្រូវបានទទួលស្គាល់នៅពេលក្រុមហ៊ុន ឌី ប៊ី ឌី បានបំពេញការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យាអតិថិជនបានរួចរាល់។ ដើម្បីទទួលស្គាល់ចំណូល ក្រុមហ៊ុន ឌី ប៊ី ឌី បានអនុវត្ត ៥ ជំហាន គឺ៖

១.កំណត់កិច្ចសន្យាជាមួយអតិថិជន

២.កំណត់ពីការអនុវត្តកាតព្វកិច្ច

៣.កំណត់ពីថ្លៃប្រតិបត្តិការ

៤.ការបែងចែកថ្លៃប្រតិបត្តិការធៀបនឹងការអនុវត្តកាតព្វកិច្ច

៥.ទទួលស្គាល់ចំណូលនៅពេល/ការអនុវត្តកាតព្វកិច្ចត្រូវបានពេញចិត្ត។

### ២-ការវិភាគចំណូលតាមផ្នែក

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី មានចំណូលសចំនួន ១៦.៣៧៦.៩៨៧ ពាន់រៀល ដែលកើនឡើងចំនួន ២០៧.៦៣៧ ពាន់រៀល ស្មើនឹង ១,២៨ ភាគរយ បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០២២។ ការកើនឡើងនេះបណ្តាលមកពីចំណូលពីគម្រោងសាងសង់កើនឡើងចំនួន ១,៥៩ ភាគរយ។

### ៣-ការវិភាគគម្លាតចំណេញដុល

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានចំណេញដុលចំនួន ៤.៣៦១.៣២៤ ពាន់រៀល កើនឡើងចំនួន ៥០១.១៩០ ពាន់រៀល ស្មើនឹង ១២,៩៨ ភាគរយ បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០២២។ ការចំណេញនេះបណ្តាលមកពីការកើនឡើងនៃចំណូល។

### ៤-ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| តារាងសង្ខេប<br>ប្រាក់ចំណេញ | ត្រីមាសទី១ ឆ្នាំ២០២៣<br>(ពាន់រៀល) | ត្រីមាសទី១ ឆ្នាំ២០២២<br>(ពាន់រៀល) | បម្រែបម្រួល<br>(ពាន់រៀល) | បម្រែបម្រួល<br>% |
|---|---|---|---|---|
| ចំណេញដុល | ៤.៣៦១.៣២៤ | ៣.៨៦០.១៣៤ | ៥០១.១៩០ | ១២,៩៨% |
| ចំណូលផ្សេងៗ | ៣.៥៤៥ | ១២.២៩៩ | (៨.៧៥៤) | -៧១,១៨% |
| ចំណាយប្រតិបត្តិការ | (១.៤៩១.៥៩៩) | (១.៧២៦.៦៤៩) | (២៣៥.០៥០) | -១៣,៦១% |
| ចំណាយហិរញ្ញវត្ថុ | (៤២៧.១៣៣) | (៤៧៨.៩៥៩) | (៥១.៨២៦) | -១០,៨២% |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **២.៤៤៦.១៣៧** | **១.៦៦៦.៨២៥** | **៧៧៩.៣១២** | **៤៦,៧៥%** |

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានចំណេញមុនបង់ពន្ធចំនួន ២.៤៤៦.១៣៧ ពាន់រៀល ដែលការចំណេញនេះបានកើនឡើងចំនួន ៧៧៩.៣១២ ពាន់រៀល ស្មើនឹង ៤៦,៧៥ ភាគរយ បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០២២។ មូលហេតុចម្បងដែលធ្វើឱ្យចំណេញមានការកើនឡើង ដោយសារតែមានការកើនឡើងនូវចំណេញដុលចំនួន ១២,៩៨ ភាគរយ និងមានការថយចុះនូវចំណាយប្រតិបត្តិការចំនួន ១៣,៦១ ភាគរយ និងចំណាយហិរញ្ញប្បទានមានការថយចុះចំនួន ១០,៨២%។

## ៥-ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| តារាងសង្ខេបប្រាក់ចំណេញ | ត្រីមាសទី១ ឆ្នាំ២០២៣ (ពាន់រៀល) | ត្រីមាសទី១ ឆ្នាំ២០២២ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល) | បម្រែបម្រួល % |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ | ២.៤៤៦.១៣៧ | ១.៦៦៦.៨២៥ | ៧៧៩.៣១២ | ៤៦,៧៥% |
| ចំណាយពន្ធលើប្រាក់ចំណូល | (៣៥៤.៣៥៦) | (១០៩.៥០២) | ២៤៤.៨៥៤ | ២២៣,៦១ % |
| **ចំណេញក្នុងការិយបរិច្ឆេទ** | **២.០៩១.៧៨១** | **១.៥៥៧.៣២៣** | **៥៣៤.៤៥៨** | **៣៤,៣២ %** |

ចំពោះពន្ធលើប្រាក់ចំណូល ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ត្រូវបង់ចំនួន ២០ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធ ដោយកាត់កងជាមួយប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ ចំនួន ១ ភាគរយ នៃចំណូលប្រចាំឆ្នាំសរុប។

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទទួលបានចំណេញក្នុងការិយបរិច្ឆេទចំនួន ២.០៩១.៧៨១ ពាន់រៀល ដែលការកើនឡើងចំណេញបានកើនឡើងចំនួន ៥៣៤.៤៥៨ ពាន់រៀល ស្មើនឹង ៣៤,៣២ ភាគរយ បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០២២។ មូលហេតុចម្បងដែលធ្វើឱ្យមានការកើនឡើងនៃប្រាក់ចំណេញនេះ គឺដោយសារមានការកើនឡើងនៃប្រាក់ចំណេញមុនបង់ពន្ធ។

## ៦-ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទទួលបានលទ្ធផលចំណេញលម្អិតក្នុងការិយបរិច្ឆេទ ចំនួន ១.៥៩៤.១៥៥ ពាន់រៀល ដែលកើនឡើងចំនួន ២៥៨.៣៧៣ ពាន់រៀល ស្មើនឹង ១៩,៣៤ ភាគរយ បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០២២។ មូលហេតុចម្បងដែលធ្វើឱ្យមានការកើនឡើងនៃប្រាក់ចំណេញនេះ គឺដោយសារមានការកើនឡើងនៃប្រាក់ចំណេញមុនបង់ពន្ធ។

## ៧-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានកត្តា និងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលគួរឱ្យកត់សម្គាល់ឡើយ។

**ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានវិភាគកត្តាសំខាន់ៗដូចខាងក្រោម ដែលអាចមានផលប៉ះពាល់ដល់លទ្ធភាពរកប្រាក់ចំណេញដល់ក្រុមហ៊ុន។

**១-ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់**

យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទិន្នន័យសំណង់ទូទាំងប្រទេសមានចំនួន ៤.២៧៦ គម្រោង ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបចំនួន ៧.២៨៩.៧៦៥ ម៉ែត្រការ៉េ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ ២.៩៧២.២៦០.៩២៨ ដុល្លារអាមេរិក មានការថយចុះចំនួន ៤៤,២៧ ភាគរយ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ មានចំនួន ៤.៣០៣ គម្រោង មានផ្ទៃក្រឡាកម្រាលសំណង់ចំនួន ១២.៩៩៨.០៧២ ម៉ែត្រការ៉េ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ៥.៣៣៣.៧៩៨.៥២៥ ដុល្លារអាមេរិក។

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក គឺជាក្រុមហ៊ុនសំណង់ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើការផ្តល់សេវាកម្ម MEP ដែលមានដូចជា (១)ផ្នែកមេកានិច និងអគ្គិសនី (២)ប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ (៣)កម្តៅខ្យល់ចេញចូល និងប្រព័ន្ធម៉ាស៊ីនត្រជាក់ (៤) សំណង់ស៊ីវិល និង (៥) ការថែទាំអគារ។

**២-ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានរួមបញ្ចូលការឡើងអតិផរណាដែលបានរំពឹងទុកនៅក្នុងសំណើរដែលដាក់ដេញថ្លៃគម្រោង។ ប្រសិនបើតម្លៃនៃវត្ថុធាតុដើមប្រែប្រួលស្របតាមអត្រាអតិផរណា វានឹងមិនមានផលប៉ះពាល់ខ្លាំងដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុននោះទេ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើតម្លៃសម្ភារៈកើនឡើងខ្លាំង វានឹងធ្វើឱ្យក្រុមហ៊ុនខាតបង់។

**៣-ការវិភាគលើពន្ធ**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានទទួលនូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូល ៥០ ភាគរយសម្រាប់រយៈពេល៣ឆ្នាំ ដោយគិតចាប់ពីឆ្នាំ ២០២២ ដល់ ២០២៤។ ដោយអនុលោមតាមច្បាប់ពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ឌី ប៊ី ឌី មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលក្នុងអត្រា ២០ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធ។ ក្រៅពីពន្ធលើប្រាក់ចំណេញ ក្រុមហ៊ុនក៏ត្រូវបង់ពន្ធអប្បបរមាផងដែរ។ ពន្ធអប្បបរមា ជាពន្ធប្រចាំឆ្នាំជាមួយនឹងអត្រា ១ ភាគរយ លើចំណូលប្រចាំឆ្នាំសរុប ដោយរួមបញ្ចូលពន្ធគ្រប់ប្រភេទទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម និងដោយមិនគិតពីស្ថានភាពចំណេញ ឬខាតរបស់ក្រុមហ៊ុនឡើយ។ បន្ថែមពីនេះ ក្រុមហ៊ុនបាន

គណនាអាករលើតម្លៃបន្ថែមចំនួន ១០ ភាគរយ នៅលើវិក័យបត្រដែលចេញទៅឱ្យអតិថិជន។ អាករលើតម្លៃបន្ថែម ត្រូវបានកាត់កងជាមួយអាករលើតម្លៃបន្ថែមលើធាតុចូល ១០ ភាគរយ ដែល ក្រុមហ៊ុនបានទូទាត់ទៅអ្នកផ្គត់ផ្គង់នូវរាល់ការទិញទំនិញ។ ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធកាត់ទុកលើចំណូលការប្រាក់នៅអត្រា ៤ ភាគរយ នៃប្រាក់បញ្ញើចរន្ត ដែលត្រូវបានកាត់ទុកដោយធនាគារ, បង់ពន្ធកាត់ទុកលើប្រាក់បំណាច់ ឬលាភការ របស់ក្រុមប្រឹក្សាភិបាល នៅអត្រា ១៥ ភាគរយ, បង់ពន្ធកាត់ទុកលើការចំណាយពាក់ព័ន្ធនឹងសេវាប្រឹក្សាយោបល់នៅ អត្រា ១៤ ភាគរយ (អនិវាសនជន) និង អត្រា ១៥ ភាគរយ (និវាសនជន), និងបង់ពន្ធកាត់ទុកលើចំណូលពីការជួលនៅអត្រា ១០ ភាគរយ។ ជាមួយគ្នានេះ ក្រុមហ៊ុនក៏មានកាតព្វកិច្ចបង់ពន្ធលើការនាំចូលលើសម្ភារៈ និងវត្ថុធាតុដើមនូវអត្រា ៧ ភាគរយ ទៅ ៣៥ ភាគរយ ផ្អែកលើប្រភេទទំនិញ។

**៤-ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ**

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ គណៈគ្រប់គ្រងយល់ថាក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

**គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល**

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ប្រាក់ចំណូលរបស់ ឌី ប៊ី ឌី ពីការលក់សម្ភារៈមានការថយចុះយ៉ាងគួរឱ្យកត់សម្គាល់ ប៉ុន្តែប្រាក់ចំណូលពីការសាងសង់មានការកើនឡើង ដោយសារនៅក្នុងត្រីមាសនេះ ឌី ប៊ី ឌី បានបញ្ចប់គម្រោងមួយចំនួនដូចជា Tenant Market Place, Tenant Food Court, Tenant Paradise, Decathlon Aeon 3 **និង** Tenant CMRT Office។ ហើយនៅក្នុងត្រីមាសនេះ ឌី ប៊ី ឌី ក៏ទទួលបានគម្រោងថ្មីមួយចំនួន ដែលជាហេតុធ្វើឱ្យចំណូលមានការកើនឡើង បើធៀបទៅនឹងត្រីមាសទី១ នៃឆ្នាំ២០២២។

**ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ**

**១-ផលប៉ះពាល់នៃអត្រាប្តូរប្រាក់**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុជារូបិយប័ណ្ណបរទេសផ្សេងទៀតទេ លើកលែងតែមានទឹកប្រាក់តូចមួយចំនួនសម្រាប់គណនីអ្នកផ្គត់ផ្គង់ ដែលត្រូវបង់ជារូបិយប័ណ្ណថៃបាត (THB) និង អឺរ៉ូ (EUR) ហើយរាល់កម្ចីទាំងអស់របស់ក្រុមហ៊ុនមានអត្រាថេរ ដូច្នេះក្រុមហ៊ុនមិនមានផលប៉ះពាល់ខ្លាំងពីការប្រែប្រួលនៃការប្តូររូបិយប័ណ្ណបរទេស និងអត្រាការប្រាក់ទេ។

**២-ផលប៉ះពាល់នៃអត្រាការប្រាក់**

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនទទួលរងហានិភ័យពាក់ព័ន្ធនឹងអត្រាការប្រាក់នោះទេ។

**៣-ផលប៉ះពាល់នៃថ្លៃទំនិញ**

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានផលប៉ះពាល់ជាសារវន្តលើថ្លៃទំនិញនោះទេ។

**ង-ផលប៉ះពាល់នៃអតិផរណា**

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានរួមបញ្ចូលការកើនឡើងនៃអតិផរណាដែលបានរំពឹងទុកនៅក្នុងសំណើរដែលដាក់ដេញថ្លៃគម្រោង។ ប្រសិនបើតម្លៃនៃវត្ថុធាតុដើមប្រែប្រួលស្របតាមអត្រាអតិផរណា វានឹងមិនមានផលប៉ះពាល់ខ្លាំងដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុននោះទេ។

**ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល**

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យអចលនទ្រព្យ និងសំណង់គឺជាកត្តាចម្បងមួយជំរុញកំណើនសេដ្ឋកិច្ច។ យោងតាមរបាយការណ៍របស់ CBRE ទស្សនវិស័យទីផ្សារអចលនទ្រព្យកម្ពុជាឆ្នាំ ២០១៩ ឧស្សាហកម្មសំណង់បានកើនឡើង ១៨,១ ភាគរយ រីឯនៅក្នុងឆ្នាំ ២០១៨ ចំនួនខុនដូកើនឡើងប្រហែល ១២០ ភាគរយ។ ខណៈពេលដែលកត្តាកំណើនសេដ្ឋកិច្ចចម្រុះចូលទៅក្នុងដំណើរការដ៏រឹងមាំនៃឧស្សាហកម្មសំណង់ ការវិនិយោគផ្ទាល់ពីបរទេស (FDI) គឺជាកត្តាជំរុញដ៏សំខាន់មួយនៃឧស្សាហកម្មនេះ។ ក្នុងឆ្នាំ២០១៩ FDI នៅកម្ពុជាមានចំនួន ១០,៦ ភាគរយនៃទិន្នផលក្នុងស្រុកសរុប (GDP)សរុប។ ក្នុងឆ្នាំ២០១៨ ការវិនិយោគផ្ទាល់ពីបរទេសបានឈានដល់កម្រិតខ្ពស់បំផុតដោយកើនឡើង ១០,៧ ភាគរយ ឬ ៣០០ លានដុល្លាអាមេរិក ពី ២,៨ ពាន់លានដុល្លាអាមេរិក ក្នុងឆ្នាំ២០១៧ ដល់ ៣,១ ពាន់លានដុល្លាអាមេរិក ក្នុងឆ្នាំ២០១៨ (ធនាគារពិភពលោក)។ ការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ក្នុងស្រុក ការកែតម្រូវទីផ្សារអចលនទ្រព្យបន្ទាប់ពីការសាងសង់អូសបន្លាយពេលយូរ និងការរីកដុះដាលនៃអចលនទ្រព្យ ការផ្តល់ឥណទានកើនឡើងដល់វិស័យសំណង់/អចលនទ្រព្យ/កម្ចីទិញផ្ទះ (ដែលថ្មីៗនេះពឹងផ្អែកខ្លាំងលើការវិនិយោគរបស់ចិន) និងឥណទាន គឺជាចំណុចខ្សោយនៃឧស្សាហកម្មបច្ចុប្បន្ន។

## ផ្នែកទី ៥.-ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

- ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានព័ត៌មានគួរឱ្យកត់សម្គាល់ផ្សេងទៀតក្រៅពីព័ត៌មានដែលបានបង្ហាញក្នុងរបាយការណ៍នេះទេ។

## ហត្ថលេខាអភិបាលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង

**កាលបរិច្ឆេទ៖ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣**

**បានអាន និងឯកភាព**

--------------------

**លោក នាង វិធី**

**ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង**

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
# និង
# ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល

# ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ និងសម្រាប់ដំណាច់
ការិយបរិច្ឆេទ ៣ខែដែលបានបញ្ចប់

# មាតិកា


| | ទំព័រ |
|---|---|
| **របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** | ១ |
| **ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** | |
| របាយការណ៍ស្តីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ២ - ៣ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ៤ - ៥ |
| របាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល | ៦ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | ៧ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល | ៨ - ៩ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ១០ - ២៧ |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ភ្ជាប់ជាមួយនឹងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ព្រមទាំងរបាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែដែលបានបញ្ចប់ និងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្ត ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។

ជំនួសឱ្យក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក
DBD ENGINEERING Plc.
KINGDOM OF CAMBODIA

**លោក នាង វិធី**
**ប្រធានក្រុមប្រឹក្សាភិបាល**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣

Grant Thornton

# របាយការណ៍ស្ដីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

**ជូនចំពោះភាគហ៊ុនិករបស់**
**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

យើងខ្ញុំបានធ្វើការត្រួតពិនិត្យទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ព្រមទាំងរបាយការណ៍ចំណូលលម្អិតចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែដែលបានបញ្ចប់ រួមទាំងសេចក្តីពន្យល់លើកំណត់សម្គាល់ ("ព័ត៌មានហិរញ្ញវត្ថុ")។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញជូននូវរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើសេចក្តីសន្និដ្ឋានទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ដោយផ្អែកទៅលើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យដោយអនុលោមតាមស្តង់ដារអន្តរជាតិនៃកម្ពុជា លើការត្រួតពិនិត្យលេខ ២៤១០ ស្តីពី *ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់អង្គភាព*។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមមានការចោទសួរជាចម្បងទៅកាន់បុគ្គលដែលទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុរួមទាំងការអនុវត្តតាមនីតិវិធីក្នុងការវិភាគ និងនីតិវិធីក្នុងការត្រួតពិនិត្យផ្សេងទៀត។ ការត្រួតពិនិត្យនេះមានវិសាលភាពតិចជាងការធ្វើសវនកម្ម ដែលធ្វើឡើងដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ដូច្នេះហើយ យើងខ្ញុំមិនធានាថា យើងខ្ញុំនឹងដឹងអំពីបញ្ហាសំខាន់ៗទាំងអស់ដែលអាចនឹងត្រូវបានកំណត់អត្តសញ្ញាណដូចការធ្វើសវនកម្មនោះទេ។ ហេតុនេះហើយ យើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មទេ។

## សេចក្តីសន្និដ្ឋាន

ផ្អែកទៅលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានបញ្ហាណាមួយគួរឱ្យកត់សម្គាល់ ដែលជាហេតុធ្វើឱ្យយើងខ្ញុំមានការជឿជាក់ថា ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន មិនបានរៀបចំត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* នោះទេ។

គណនេយ្យករជំនាញ និងសវនករប្រតិស្រុត
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

Grant Thornton

**បញ្ហាផ្សេងៗ**

ព័ត៌មានប្រៀបធៀបក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺអាស្រ័យទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។ ព័ត៌មានប្រៀបធៀបសម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ក្នុងរបាយការណ៍ចំណូលលម្អិត របាយការណ៍លំហូរសាច់ប្រាក់ រួមទាំងសេចក្តីពន្យល់ក្នុងកំណត់សម្គាល់ មិនត្រូវបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្មឡើយ។

Grant Thornton

ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) | | (បានធ្វើសវនកម្ម) | |
|---|---|---|---|---|---|
| | | ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| ទ្រព្យសកម្ម | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ - សុទ្ធ | ៦ | **៤.៥៨៤.៣៤២** | **១៨.៥៨៤.៩២២** | ៤.១០៣.៧៣៨ | ១៦.៨៩៥.០៨៩ |
| ទ្រព្យសកម្មអរូបី - សុទ្ធ | ៧ | **៤២.៣០៣** | **១៧១.៤៩៦** | ៤៣.៧៤៥ | ១៨០.០៩៨ |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | ៩ | **២០.១០០** | **៨១.៤៨៥** | ២០.១០០ | ៨២.៧៥២ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | **៤.៦៤៦.៧៤៥** | **១៨.៨៣៧.៩០៣** | ៤.១៦៧.៥៨៣ | ១៧.១៥៧.៩៣៩ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១០ | **៦៧.០៦៦** | **២៧១.៨៨៦** | ២១.៤៦៤ | ៨៨.៣៦៧ |
| ប្រាក់តម្កល់ធានាដើមទុន | ១១ | **៦៥១.២១៨** | **២.៦៤០.០៣៨** | ៥៩០.០៨០ | ២.៤២៩.៣៥៩ |
| គណនីពាណិជ្ជត្រូវទទួល | ១២ | **២.៧៨៦.៨៥១** | **១១.២៩៧.៨៩៤** | ៣.១៦៥.៧៧៣ | ១៣.០៣៣.៤៨៧ |
| សន្និធិ - សុទ្ធ | ១៣ | **១.៣៨៤.៧១៤** | **៥.៦១៣.៦៣១** | ១.២៧៤.១៣២ | ៥.២៤៥.៦០១ |
| ទ្រព្យសកម្មកិច្ចសន្យា | ១៤ | **៥.៩០០.២៥១** | **២៣.៩១៩.៦១៨** | ៤.៣៣៨.៧៧២ | ១៧.៨៦២.៧២៤ |
| សមតុល្យដែលភាគហ៊ុនិកជំពាក់ | ២៦ | **១៣៦.២៧០** | **៥៥២.៤៣៩** | ១៣៦.២៧០ | ៥៦១.០២៤ |
| ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ | ១៥ | **១.២៤៥.៩១៧** | **៥.០៥០.៩៤៦** | ១.០៦២.២៣៧ | ៤.៣៧៣.២៣០ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | **១២.១៧២.២៨៧** | **៤៩.៣៤៦.៤៥២** | ១០.៥៨៨.៧២៨ | ៤៣.៥៩៣.៧៩២ |
| **ទ្រព្យសកម្មសរុប** | | **១៦.៨១៩.០៣២** | **៦៨.១៨៤.៣៥៥** | ១៤.៧៥៦.៣១១ | ៦០.៧៥១.៧៣១ |
| **មូលធន** | | | | | |
| ដើមទុន | ១៦ | **៤.៦១៥.៣៨៥** | **១៨.៧៨៦.៦៨៧** | ៤.៦១៥.៣៨៥ | ១៨.៧៨៦.៦៨៧ |
| បុព្វលាភភាគហ៊ុន | ១៦.១ | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ |
| ប្រាក់ចំណេញរក្សាទុក | | **១.៣៩៣.៥៧៩** | **៥.៨១០.៧៤៨** | ៨៨១.៣៩០ | ៣.៧១៨.៩៦៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណបម្រុងទុកបង្គរ | | **-** | **(២៧៧.៣១០)** | - | ២២០.៣១៦ |
| **មូលធនសរុប** | | **៨.១៦៧.១១៨** | **៣៣.១០៩.៤៩៥** | ៧.៦៥៤.៩២៩ | ៣១.៥១៥.៣៤១ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចី - ដកចេញនូវចំណែករយៈពេលខ្លី | ១៧ | **១.៥២២.៨៥៨** | **៦.១៧៣.៦៦៦** | ៥៩៩.៨៦៣ | ២.៤៦៩.៦៣៦ |
| **បំណុលរយៈពេលវែងសរុប** | | **១.៥២២.៨៥៨** | **៦.១៧៣.៦៦៦** | ៥៩៩.៨៦៣ | ២.៤៦៩.៦៣៦ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) | | (បានធ្វើសវនកម្ម) | |
|---|---|---|---|---|---|
| | | ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **បំណុលរយៈពេលខ្លី** | | | | | |
| ប្រាក់កម្ចី | ១៧ | **១.៤១១.១០២** | **៥.៧២០.៦០៨** | ៨៩៣.៧៨៣ | ៣.៦៧៩.៧០៥ |
| គណនីអនាគតរបស់ | ១៨ | **២.៩២៧.៥១៥** | **១១.៨៦៨.១៤៦** | ២.៤១០.៩៨៤ | ៩.៩២៦.០២០ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | ១៩ | **១.៣៦៩.៣២២** | **៥.៥៥១.២៣១** | ១.០៨០.២៤៤ | ៤.៤៤៧.៣៦៥ |
| បំណុលកិច្ចសន្យា | ១៤ | **១.៤០៩.៨៦៣** | **៥.៧១៥.៥៨៥** | ២.១០៥.២៥៤ | ៨.៦៦៧.៣៣១ |
| បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន | ២៥.៣ | **១១.២៥៤** | **៤៥.៦២៤** | ១១.២៥៤ | ៤៦.៣៣៣ |
| **បំណុលរយៈពេលខ្លី** | | **៧.១២៩.០៥៦** | **២៨.៩០១.១៩៤** | ៦.៥០១.៥១៩ | ២៦.៧៦៦.៧៥៤ |
| **បំណុលសរុប** | | **៨.៦៥១.៩១៤** | **៣៥.០៧៤.៨៦០** | ៧.១០១.៣៨២ | ២៩.២៣៦.៣៩០ |
| **មូលធន និងបំណុលសរុប** | | **១៦.៨១៩.០៣២** | **៦៨.១៨៤.៣៥៥** | ១៤.៧៥៦.៣១១ | ៦០.៧៥១.៧៣១ |

# របាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល

| | | **(បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម)** | | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) | |
|---|---|---|---|---|---|
| | | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ | |
| | កំណត់សម្គាល់ | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៣)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| ចំណូល | ២០ | **៤.០១០.០៣៦** | **១៦.៣៧៦.៩៨៧** | ៣.៩៧៩.៦៥៨ | ១៦.១៦៩.៣៥០ |
| ថ្លៃដើមសេវាកម្ម និងទំនិញបានលក់ | ២១ | **(២.៩៤២.១៣១)** | **(១២.០១៥.៦៦៣)** | (៣.០២៩.៥៨៨) | (១២.៣០៩.២១៦) |
| **ចំណេញដុល** | | **១.០៦៧.៩០៥** | **៤.៣៦១.៣២៤** | ៩៥០.០៧០ | ៣.៨៦០.១៣៤ |
| ចំណូលផ្សេងៗ | ២៣ | **៨៦៨** | **៣.៥៤៥** | ៣.០២៧ | ១២.២៩៩ |
| ចំណាយប្រតិបត្តិការ | ២២ | **(៣៦៥.២៣០)** | **(១.៤៩១.៥៩៩)** | (៤២៤.៩៦៩) | (១.៧២៦.៦៤៩) |
| ចំណាយហិរញ្ញវត្ថុ | ២៤ | **(១០៤.៥៨៧)** | **(៤២៧.១៣៣)** | (១១៧.៨៨៣) | (៤៧៨.៩៥៩) |
| **ចំណេញមុនបង់ពន្ធ** | | **៥៩៨.៩៥៦** | **២.៤៤៦.១៣៧** | ៤១០.២៤៥ | ១.៦៦៦.៨២៥ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៥.១ | **(៨៦.៧៦៧)** | **(៣៥៤.៣៥៦)** | (២៦.៩៥១) | (១០៩.៥០២) |
| **ចំណេញក្នុងការិយបរិច្ឆេទ** | | **៥១២.១៨៩** | **២.០៩១.៧៨១** | ៣៨៣.២៩៤ | ១.៥៥៧.៣២៣ |
| ខាតលម្អិតផ្សេងៗ - | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **(៤៩៧.៦២៦)** | - | (២២១.៥៤១) |
| **ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | | **៥១២.១៨៩** | **១.៥៩៤.១៥៥** | ៣៨៣.២៩៤ | ១.៣៣៥.៧៨២ |

ចំណេញក្នុងមួយសន្លឹកហ៊ុន ដែលបែងចែកទៅឱ្យភាគហ៊ុនិករបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ចំណេញមូលដ្ឋានក្នុងមួយភាគហ៊ុន | **២៩** | **០,០៣** | **០,១១** | ០,០២ | ០,០៩ |
| ចំណេញថយចុះក្នុងមួយភាគហ៊ុន | **២៩** | **០,០៣** | **០,១១** | ០,០២ | ០,០៩ |

# របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល

| | ដើមទុន | | បុព្វលាភភាគហ៊ុន | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ បម្រុងទុកបង្គរ | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) | | | | | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | **៨៨១.៣៨៩** | **៣.៧១៨.៩៦៨** | **២២០.៣១៦** | **៧.៦៥៤.៩២៩** | **៣១.៥១៥.៣៤១** |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | **៥១២.១៨៩** | **២.០៩១.៧៨០** | - | **៥១២.១៨៩** | **២.០៩១.៧៨០** |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | **(៤៩៧.៦២៦)** | - | **(៤៩៧.៦២៦)** |
| **សមតុល្យនាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣** | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | **១.៣៩៣.៥៧៨** | **៥.៨១០.៧៤៨** | **(២៧៧.៣១០)** | **៨.១៦៧.១១៨** | **៣៣.១០៩.៤៩៥** |
| (បានធ្វើសវនកម្ម) | | | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ | ២.២៨១.៦៦៤ | ៩.៤៤១.៨៨៧ | (១២៧.០៤៧) | ៩.០៥៥.២០៣ | ៣៦.៨៩០.៨៩៧ |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | (១.១៩២.១៤៦) | (៤.៨៧២.៣០០) | - | (១.១៩២.១៤៦) | (៤.៨៧២.៣០០) |
| ភាគលាភបានបង់ | - | - | - | - | (២០៨.១២៨) | (៨៥០.៦១៩) | - | (២០៨.១២៨) | (៨៥០.៦១៩) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | ៣៤៧.៣៦៣ | - | ៣៤៧.៣៦៣ |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ | ៨៨១.៣៩០ | ៣.៧១៨.៩៦៨ | ២២០.៣១៦ | ៧.៦៥៤.៩២៩ | ៣១.៥១៥.៣៤១ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ | | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **លំហូរសាច់ប្រាក់បានពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | ៥៩៨.៩៥៦ | ២.៤៤៦.១៣៦ | ៤១០.២៤៥ | ១.៦៦៦.០០៥ |
| **និយ័តកម្មសម្រាប់៖** | | | | | |
| រំលស់លើទ្រព្យរូបី និងអរូបី | | ៤០.១៥៣ | ១៦៣.៩៨៥ | ៥១.៥១៧ | ២០៩.២១២ |
| ចំណាយហិរញ្ញវត្ថុ | ២៤ | ១០៤.៥៨៧ | ៤២៧.១៣៣ | ១៨៨ | ៧៦៣ |
| ចំណូលការប្រាក់ | | (១០៤.៥៨៧) | (៤២៧.១៣៣) | - | - |
| ខាតលើការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | (៣) | (១២) | ១១៧.៨៨៣ | ៤៧៨.៧២៣ |
| ចំណេញលើការប្តូររូបិយប័ណ្ណបរទេស | | (៣) | (១២) | - | - |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | ៧៤៣.៩៦១ | ៣.០៣៨.៣៣៧ | ៥៧៩.៨៣៣ | ២.៣៥៤.៧០៣ |
| **បម្រែបម្រួលទុនបង្វិល** | | | | | |
| បម្រែបម្រួលសុទ្ធក្នុង៖ | | | | | |
| ទ្រព្យសកម្មកិច្ចសន្យា | | (១.៥៦១.៤៧៩) | (៦.៣៧៧.០៨០) | ៨៧២.៣៤៥ | ៣.៥៤២.៥៩៣ |
| ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ | | (១៨៣.៦៧៦) | (៧៥០.១៣៣) | (២១៥.៥១១) | (៨៧៥.១៩០) |
| សន្និធិ - សុទ្ធ | | (១១០.៥៨២) | (៤៥១.៦១៧) | ៧៥៦.៩៤២ | ៣.០៧៣.៩៤១ |
| ប្រាក់តម្កល់ធានាដើមទុន | | (៦១.១៣៨) | (២៤៩.៦៨៨) | (៤១៥.០០០) | (១.៦៨៥.៣១៥) |
| គណនីពាណិជ្ជត្រូវទទួល | | ៣៧៨.៩២២ | ១.៥៤៧.៥១៧ | ៩៤៤.៧១៣ | ៣.៨៣៦.៤៧៩ |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | | - | - | (៥០) | (២០៣) |
| ឥណទានវិបារូបន៍ | | ៥១៦.៥៣១ | ២.១០៩.៥១៣ | (៣៦១.៨៥៧) | (១.៤៦៩.៥០១) |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | | ២៨៩.០៧៨ | ១.១៨០.៥៩៥ | (៧៤៣.៤៥១) | (៣.០១៩.១៥៥) |
| បំណុលកិច្ចសន្យា | | (៦៩៥.៣៩១) | (២.៨៣៩.៩៧៧) | ៧៩៤.៦៧៨ | ៣.២២៧.១៨៧ |
| **សាច់ប្រាក់ (បានប្រើក្នុង)/បានពីប្រតិបត្តិការ** | | (៧៨៨.៦៣២) | (៣.២២០.៧៧៣) | ២.២១២.៦៤២ | ៨.៩៨៥.៥៣៩ |
| ការប្រាក់បានទទួល | | ១០៤.៥៨៧ | ៤២៧.១៣៣ | - | - |
| ពន្ធលើប្រាក់ចំណូលបានបង់ | ២៥.៣ | (៨៦.៧៦៧) | (៣៥៤.៣៥៦) | (២៦.៩៥១) | (១០៩.៤៤៨) |
| **សាច់ប្រាក់សុទ្ធ (បានប្រើក្នុង)/បានពីសកម្មភាពប្រតិបត្តិការ** | | (៧៧០.៨១២) | (៣.១៤៧.៩៩៦) | ២.១៨៥.៦៩១ | ៨.៨៧៦.០៩១ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# របាយការណ៍លំហូរសាច់ប្រាក់ចន្លោះពេល (ត)

| | | | | | |
|---|---|---|---|---|---|
| | | **(បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម)** | | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) | |
| | | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ | |
| | | **ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣** | | ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ | |
| | កំណត់សម្គាល់ | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៣)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ និង ទ្រព្យសកម្មអរូបី | ៦ និង ៧ | **(៥១៩.៣៦៧)** | **(២.១២១.០៩៥)** | (១៦៦.១៨០) | (៦៧៤.៨៥៦) |
| ចំណូលពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | **៥៥** | **២២៥** | - | - |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | **(៥១៩.៣១២)** | **(២.១២០.៨៧០)** | (១៦៦.១៨០) | (៦៧៤.៨៥៦) |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ការទូទាត់សងប្រាក់កម្ចី | ១៧ | **(៩២៨.៦០០)** | **(៣.៧៩២.៤០២)** | (៤.២០២.៩៨៦) | (១៧.០៦៨.៣២៧) |
| ការទទួលបានប្រាក់កម្ចី | ១៧ | **២.៣៦៨.៩១៤** | **៩.៦៧៤.៦៤៥** | ២.៨០០.៣៨៥ | ១១.៣៧២.៣៦៤ |
| ការទូទាត់ការប្រាក់ | ១៧ | **(១០៤.៥៨៧)** | **(៤២៧.១៣៣)** | (១១៧.៨៨៣) | (៤៧៨.៧២៣) |
| ការទូទាត់សងបំណុលភតិសន្យា | ៨ | - | - | (១៥.៧៩៨) | (៦៤.១៥៦) |
| **សាច់ប្រាក់សុទ្ធបានពី/(បានប្រើក្នុង)សកម្មភាពហិរញ្ញវត្ថុ** | | **១.៣៣៥.៧២៧** | **៥.៤៥៥.១១០** | (១.៥៣៦.២៨២) | (៦.២៣៨.៨៤២) |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់ សមមូលសុទ្ធក្នុងអំឡុងការិយបរិច្ឆេទ** | | **៤៥.៦០២** | **១៨៦.២៤៤** | ៤៨៣.២២៩ | ១.៩៦២.៣៩៦ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល ដើមការិយបរិច្ឆេទ | | **២១.៤៦៤** | **៨៨.៣៦៧** | ២២៥.១២០ | ៩១៧.១៣៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **(២.៧២៥)** | - | (១០.៧១៧) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងការិយបរិច្ឆេទ** | | **៦៧.០៦៦** | **២៧១.៨៨៦** | ៧០៨.៣៤៩ | ២.៨៦៨.៨១៣ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

## ១. អំពីក្រុមហ៊ុន

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ ជាមួយវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ 00004០២៩ ពីក្រសួងពាណិជ្ជកម្ម។ ដោយអនុលោមតាមអនុស្សរណៈ និងលក្ខន្តិកៈ ដែលអនុញ្ញាតក្រុមហ៊ុនឱ្យដំណើរការអាជីវកម្មសម្រាប់រយៈពេល ៩៩ឆ្នាំ គិតចាប់ផ្តើមពីកាលបរិច្ឆេទចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជី និងទីតាំងអាជីវកម្មចម្បងរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅដីឡូតិ៍លេខ៦៨ ផ្លូវ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ប្រអប់សំបុត្រ ១៧៨ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺ ធ្វើប្រតិបត្តិការជាអ្នកម៉ៅការផ្នែកមេកានិក និងអគ្គិសនី អ្នកម៉ៅការប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ ប្រព័ន្ធម៉ាស៊ីនត្រជាក់ក្នុងបន្ទប់ HVAC និងអ្នកម៉ៅការថែទាំអគារផ្សេងៗ។

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១ ក្រុមហ៊ុនត្រូវបានចុះបញ្ជីដោយជោគជ័យលើកំណើននៃផ្សារមូលបត្រកម្ពុជា ("CSX")។ ភាគហ៊ុនថ្មីដែលបានបោះផ្សាយមានចំនួន ៦.៤៦១.៥៣៨ ហ៊ុនដែលមានតម្លៃចារឹក ១.០០០ រៀល (០.២៥ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន ក្នុងតម្លៃលក់ចេញ ២.៣៨០ រៀល (០.៥៨ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន។ ក្រុមហ៊ុនបានទទួលសាច់ប្រាក់ពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ("IPO") ក្នុងសមតុល្យ ៣.៧៧៣.៥៣៩ ដុល្លារអាមេរិក ជាលទ្ធផលក្នុងបុព្វលាភភាគហ៊ុនគឺ ២.១៥៨.១៥៤ ដុល្លារអាមេរិក (៨.៧៧៩.៣៧០.០០០ រៀល)។ តាមអនុស្សរណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវបានរំពឹងទុកថានឹងធ្វើបច្ចុប្បន្នភាពក្នុងខែឧសភា ឆ្នាំ២០២៣។

គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ក្រុមហ៊ុនមាននិយោជិតចំនួន ៩៦០ នាក់ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២៖ មានចំនួន ១.១១២ នាក់)។

## ២. មូលដ្ឋាននៃការរៀបចំ

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែដែលបានបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ ៣៤ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល ("CIAS ៣៤")។ ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ មិនបានរួមបញ្ចូលកំណត់សម្គាល់ទាំងអស់ដូចនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចប្រចាំឆ្នាំនោះទេ។ ដូច្នេះហើយ របាយការណ៍នេះត្រូវបានអានដោយភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដែលត្រូវបានរៀបចំឡើងស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានប្រើក្នុងការរៀបចំរបាយការណ៍ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ គឺស្របតាមគោលនយោបាយគណនេយ្យសំខាន់ៗដែលបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

## ៣. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ប៉ុន្តែដោយសារក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមជាប្រាក់ដុល្លារអាមេរិក("USD") ក្រុមប្រឹក្សាភិបាលបានកំណត់យករូបិយប័ណ្ណប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់គោលបំណងក្នុងការវាស់វែង និងការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចក្រោមព្រឹត្តិការណ៍ និងស្ថានភាពរបស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ក្រៅពីប្រាក់ដុល្លារអាមេរិក គឺត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ក្នុងអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងបំណុលជារូបិយវត្ថុ កំណត់ដោយរូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិកនាកាលបរិច្ឆេទរបាយការណ៍ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ លម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតឡើងពីការប្តូរប្រាក់ គឺត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតផ្សេងៗ។

